**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**
សំណុំរឿង រដ្ឋប្បវេណី
លេខៈ៣៧៥
ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៩
**សាលដីកា**
លេខៈ១១៤
ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០០

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**
បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០០ ដោយមានសមាសភាពដូចតទៅៈ
១-ឯកឧត្តម ........... ជាប្រធាន
២-លោក ............ ជាចៅក្រម
៣-លោក .......... ជាចៅក្រម
៤-លោក ........... ជាចៅក្រម
៥-លោក .............. ជាចៅក្រម
ជំនួសលោក..............ដែលជាចៅក្រមរបាយការណ៍

**ក្រឡាបញ្ជី**
-លោក .................

**តំណាងមហាអយ្យការ**
-លោក ............. ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរៈ លើបណ្តឹងសាទុក្ខពីសាលដីកាលេខ៥០៩ ចុះថ្ងៃទី២៩ ខែកក្កដាឆ្នាំ១៩៩៩ នៃសំណុំរឿងរដ្ឋប្បវេណីលេខ០៥ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៨៩ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះចវេ ភេទប្រុសអាយុ៣៩ ឆ្នាំ ជាតិចិន មុខរបរ ពាហិជ្ជករ មានទីលំនៅផ្ទះលេខ២០៦ ផ្លូវព្រះសីហនុ សង្កាត់បឹងកេងកង ខណ្ឌចំការមន ក្រុងភ្នំពេញ ។ ឪពុកឈ្មោះចាវ វិនអ៊ី(ស) ម្តាយឈ្មោះគួ យ៉ាលឹង(រ) ប្រពន្ធឈ្មោះសថវ មានកូនពីរនាក់ ។

មានមេធាវីលោក................។

និងចុងបណ្តឹងសាទុក្ខឈ្មោះលហភេទប្រុសអាយុ៥២ឆ្នាំ ជាតិចិន កាន់លិខិត ឆ្លងដែន លេខ ៨៣៩២០៧ របរកស៊ីពាណិជ្ជករ មានទីលំនៅក្រុមហ៊ុនយូតាយឡុង តូបាកូ ប្រដាក់ កូអិល ជីឌី ផ្ទះលេខ ២០៦ ផ្លូវព្រះសីហនុ សង្កាត់បឹងកេងកង ។ ខណ្ឌចំការមន ក្រុងភ្នំពេញ ។ ទីតាំងរោងចក្រដួលេខ១៧១ សង្កាត់ទឹកល្អក់ទី៣ ខណ្ឌទួលគោក ក្រុងភ្នំពេញ ។

និងចុងបណ្តឹងសាទុក្ខឈ្មោះសយភេទប្រុសអាយុ៥៥ឆ្នាំ ជាតិចិន មុខរបរពាណិជ្ជករ កាន់លិខិតឆ្លងលេខ P 1304934 ទីលំនៅប្រុមហ៊ុន យូតាយឡុង ផ្ទះលេខ២០៦ ផ្លូវព្រះសីហនុសង្កាត់បឹងកេងកង២

ខណ្ឌចំការមន ក្រុងភ្នំពេញ ទីតាំងរោងចក្រ ផ្លូវលេខ២៧១ សង្កាត់ទឹកល្អក់៣ ខណ្ឌចំការមន ក្រុងភ្នំពេញ ។

តំណាងដោយលោកជហ និងលោកមធក

មានមេធាវីលោកគី .................

អំពីវិវាទ - សុំរំលាយកិច្ចសន្យា

- សុំដកភាគហ៊ុន អាគារឃ្លាំង

-ទារជម្ងឺចិត្ត ២០ ម៉ឺនដុល្លា

បានឃើញបណ្ដឹងសាទុក្ខលេខ៤១២ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩៩ របស់លោកចវវ និង លោកស្រីសថវ ប្ដឹងមិនសុខចិត្តពីសាលដីការដ្ឋប្បវេណីលេខ៥០៩ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ លើសេចក្ដីសម្រេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ៣៧៥ ចុះថ្ងៃទី០១ ខែធ្នូឆ្នាំ១៩៩៩ របស់តុលាការកំពូល ។

តាមពាក្យបណ្ដឹង អង្គសេចក្ដី ចុះថ្ងៃទី០១-១២-៩៧ របស់ឈ្មោះចវវ និងនាងសថវ ប្ដី-ប្រពន្ធ) ជាដើមចោទថា ចុងចម្លើយឈ្មោះលហនិងឈ្មោះសយមិនបានគោរពតាមលក្ខខ័ណ្ឌនៃកិច្ចសន្យា លក្ខន្តិកៈ របស់ក្រុមហ៊ុន ដែលជាហេតុធ្វើឱ្យភាគីរបស់ខ្លួន មានការខាតបង់ យ៉ាងច្រើន អំពីការបើកក្រុមហ៊ុននេះ ហើយជាពិសេសក្នុងចម្លើយ បានបញ្ជូនមនុស្សមកស្នាក់នៅក្នុងក្រុមហ៊ុន ដោយវាតទីធ្វើជាម្ចាស់ក្រុមហ៊ុនទៀតផង ហេតុនេះខ្លួនសុំប្ដឹងទាមទារ

១- សុំរំលាយកិច្ចសន្យា( លក្ខន្តិកៈក្រុមហ៊ុន ចុះថ្ងៃទី០៩-១២-១៩៩៥ )

២- សុំដកយកភាគហ៊ុន និងចំណែកដី អាគារ និងឃ្លាំងមកវិញ

៣- សុំឱ្យសងការខូចខាត និងប្រាក់ជម្ងឺចិត្តចំនួន២០ម៉ឺន ដុល្លា

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ៦៧(ក) ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ១៩៩៨ របស់សតុលាការ ក្រុងភ្នំពេញ សម្រេចចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយ ដែលមានខ្លឹមសារ នៃសេចសម្រេចដូចតទៅ :

១- ទទួលពាក្យបណ្ដឹង របស់ដើមចោទឈ្មោះចវវ និងប្រពន្ធឈ្មោះសថវ ចុះថ្ងៃទី០១-១២-១៩៩៧ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-រំលាយកិច្ចសន្យា (លក្ខន្តិកៈក្រុមហ៊ុនយូតាយឡុង តូបាកូ ប្រូដាក់ កូអិលធីឌី) ចុះថ្ងៃទី០៩-១២- ១៩៩៥ ចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

៣-ប្រគល់ទីតាំងដែលមានដី អាគារ ឃ្លាំង រោងចក្រ ស្ថិតនៅតាមបណ្ដោយផ្លូវលេខ២៧១ សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក ក្រុងភ្នំពេញ ដែលជាភាគហ៊ុនរបស់ដើមចោទ ឱ្យទៅឈ្មោះចវវ និងប្រពន្ធឈ្មោះសថវ វិញ ចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

៤- ប្រគល់ប្រាក់១៥០០០០ USD (ដប់ប្រាំម៉ឺនកុល្លា)និង ម៉ាស៊ីនផលិតបារី ដែលជាភាគហ៊ុនរបស់ចុងចម្លើយឱ្យទៅឈ្មោះលហនិងឈ្មោះសយវិញ ចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

៥- បង្គាប់ឱ្យឈ្មោះលហនិងសយសងសោហ៊ុយបង់ខាតជាប្រាក់ចំនួន១៧០.០០០ USD (ដប់ប្រាំពីរម៉ឺនដុល្លា) និងប្រាក់ជំងឺចិត្ត៣០.០០០ USD (បីម៉ឺនដុល្លា) ឱ្យទៅដើមចោទឈ្មោះចវ និងប្រពន្ធឈ្មោះសខ ធារី វិញ ចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

សំណួម ពរលើសពីនេះបដិសេធចោល ។ ក្នុងករណីចុងចម្លើយមិនព្រមសងប្រាក់គ្រប់ចំនួនទៅឱ្យដើមចោទទេនោះ សម្រេចរឹបអូសទ្រព្យសម្បត្តិជាភាគហ៊ុនរបស់ចុងចម្លើយ ដើម្បីលក់ឡាយឡុងជានាសំណង ។

៦- បង្គាប់ឱ្យចុងចម្លើយបង់ប្រាក់ប្រដាប់ក្តី៧០០០រៀល គឺប្រាក់ចុះបញ្ជីក្តី និងពន្ធហ្នឹង១៨០០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៧០០០រៀល រង្វាន់អ្នកប្រគល់ដីកាកោះ៥០០០រៀល សរុប៧០០០រៀល តែប្រាក់នេះ ដើមចោទបានបង់រួចហើយ ។ កាលបើហួសបណ្តឹងឧទ្ធរណ៍ បង្គាប់ឱ្យចុងចម្លើយ សងប្រាក់នេះ ទៅដើមចោទៅវិញ និងឱ្យបង់ពន្ធសមាមាត្រ មួយភាគរយ លើទឹកប្រាក់ សរុបម្ភៃម៉ឺនដុល្លា អាមេរិក ។

៧- សាលក្រមនេះ ជំនុំជំរះជាសាធារណៈ ចំពោះមុខ ដើមចោទ កំបាំងមុខចុងចម្លើយ សម្រេចបើកផ្លូវឧទ្ធរណ៍ តាមកំណត់ច្បាប់ គិតចាប់ពីថ្ងៃផុតបណ្តឹងទាស់ ។

បានឃើញ បណ្តឹងទាស់ និងបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៨៨ របស់លោកជហ និងលោកម៉ា ថេពីង ទទួលសិទ្ធិពីលោកលហនិងលោកស៊ុន ដោយប្តឹងមិនសុខចិត្ត និងសាលក្រមរដ្ឋប្បវេណីលេខ២៧(ក) ចុះថ្ងៃទី២៧ ខែកុម្ភៈឆ្នាំ១៩៩៨ របស់តុលាការក្រុងភ្នំពេញ លើសាលក្រមទាំងមូល ។

បានឃើញសាលដីកា របៀបលេខ១៥ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍សម្រេចចំពោះមុខផ្ទះក្តី ដែលមានខ្លឹមសារ នៃសេចក្តីសម្រេចដូចតទៅ :

បង្អង់ចាត់របៀប អង្កេតបន្ថែម នូវចំណុចខ្វះខាតទាក់ទិននឹងរឿងក្តី និងបង្គាប់ឱ្យគូភាគី ជូនភស្តុតាងបន្ថែម ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៥០៩ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ សម្រេចចំពោះមុខគូក្តី ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១- ទទួលបណ្តឹងឧទ្ធរណ៍របស់មេវីចុងចម្លើយ ចុះថ្ងៃទី១៦-១១-១៩៩៨ ទុកជាត្រឹមត្រូវ តាមទម្រង់ និងគតិច្បាប់ ។

២- ទទួលស្គាល់លិខិតផ្ទេរសិទ្ធិជូនមេធាវី បវចករបស់ចុងចម្លើយ និងលិខិតផ្ទេរសិទ្ធិ របស់ដើមចោទ ជូនលោកមេធាវី ការ សាវុត្ថ ទុកជាត្រឹមត្រូវតាមច្បាប់ ។

៣- បដិសេធសាលក្រមលេខ២៧(ក) ចុះថ្ងៃទី២៧-០២-១៩៩៨ ០២០ភ្នំពេញ ចោលជាអសារបង់ ។

៤- ទទួលពាក្យបណ្ដឹងរបស់ដើមចោទសុំរំលាយលក្ខន្តិកៈក្រុមហ៊ុនយូតាយឡុង តូបាកូ ប្រូដាក់ កូអិលធីឌី និងសុំដកភាគហ៊ុនវិញ ព្រមទាំងបណ្ដឹងសុំឱ្យទទួលស្គាល់ភាគហ៊ុនរបស់ភាគីចុងចម្លើយ មានលក្ខណៈត្រឹមត្រូវតាមច្បាប់

៥- រំលាយលក្ខន្តិកៈក្រុមហ៊ុនយូតាយឡុង តូបាកូ ប្រូដាក់ កូអិលធីឌី ចុះថ្ងៃទី០៩-១២-១៩៩៥ ចោលជាអសារបង់ ។

៦- ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន យូ តាយឡុង តូបាកូ ប្រូដាក់កូអិលធីឌី ទាំងអស់ ព្រមទាំងទីតាំងមានអាគារ ឃ្លាំង រោងចក្រ ស្ថិតនៅបណ្ដោយផ្លូវលេខ២៧១ សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក ក្រុងភ្នំពេញ ត្រូវលក់ឡាយឡុង បែងចែកជូនភាគី ជាភាគសមាមាត្រ តាមចំនួនភាគហ៊ុនដូចខាងក្រោម :

-ឈ្មោះ ចវ ត្រូវបាន៣០ភាគរយ (សាមសិបភាគរយ)

-ឈ្មោះ សយត្រូវ បាន៣០ភាគរយ(សាមសិបភាគរយ)

-ឈ្មោះ លហត្រូវបាន៤០ភាគរយ(សែសិបភាគរយ)

៧- បង្គាប់ឱ្យឈ្មោះថា វវវ និងប្រពន្ធ សងការខាតបង់ និងជម្ងឺចិត្តទៅឱ្យចុងចម្លើយចំនួន ៥០.០០០ ដុល្លាអាមេរិក(ប្រាំម៉ឺនដុល្លា) ។ សំណូមពរលើសពីនេះ បដិសេធចោល ។

៨-កាត់យកប្រាក់ប្រដាប់ក្ដីជាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០រៀល ដែលដើមបណ្ដឹងឧទ្ធរណ៍បានបង់ទុករួចគឺពន្ធហ្នឹង និងពន្ធចុះបញ្ជី២៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០រៀល ចំណាយ ក្នុងកិច្ចប្រគល់ដីកាកោះ៥០០០រៀល និងចំណាយលើអាជ្ញាធរតុលាការ៥០០០រៀល ។

- បង្គាប់ឱ្យដើមចោទសងប្រាក់១៣០០០រៀល ទៅចុងចម្លើយវិញ ។

-បង្គាប់ឱ្យភាគីដើមបណ្ដឹងឧទ្ធរណ៍ បង់ប្រាក់៥០ ដុល្លាអាមេរិក ទៅធនាគារត្រេឌីត៏ អាស្ត្រីកូលឥណ្ឌាស៊ុយអេស៍ ជាថ្លៃ ស្រាវជ្រាវឯកសារ ដែលធនាគារទាមទារ ។

-បង្គាប់ឱ្យដើមចោទ និងចុងចម្លើយ បង់ពន្ធសមាមាត្រមួយភាគរយនៃចំណែកប្រាក់រៀងៗខ្លួន ។ ប្រាក់ពន្ធនេះ៨០% ត្រូវបានជាប្រយោជន៍ ថវិកាជាតិ និង ២០% ត្រូវបានជារង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ។

៩- សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈ ចំពោះមុខគូក្ដី បើកផ្លូវសាទុក្ខក្នុង កំណត់ច្បាប់ ។

បានឃើញបណ្ដឹងសាទុក្ខលេខ៤១២ ចុះថ្ងៃទី២៣ខែ កញ្ញា ឆ្នាំ១៩៩៩ របស់លោកចវ និងលោកស្រីសថវ ដែលប្ដឹងមិនសុខចិត្តនឹងសាលដីកាលេខ៥០៩ ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ លើសេចក្ដីសម្រេចទាំងមូល ។

បានឃើញសារណា ចុះថ្ងៃទី១៧ ខែ មករា ឆ្នាំ២០០០ របស់ឈ្មោះចវវ និងប្រពន្ធឈ្មោះសចវ

-បានឃើញសារពអាតប ចុះថ្ងៃទី២៥ ខែ កុម្ភៈ ឆ្នាំ ២០០០ របស់មេធាវីគី .................ឲ្យលោក JIN GE លោក MA TIEPING

-បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-បានស្តាប់សចក្តីសន្និដ្ឋាន របស់ណាងមហាអយ្យការថាៈ

យល់ឃើញថា បណ្តឹងសាទុក្ខរបស់ដើមចោទស្ថិតនៅក្នុងកំណត់ច្បាប់ គប្បីលើកយកមក ពិនិត្យពិចារណា ។

សូមក្រុមប្រឹក្សាជំនុំជំរះ សម្រេចតាមច្បាប់ ។

បានស្តាប់ចម្លើយរបស់ឈ្មោះចវវ ជាដើមចោទ និង ជាដើមបណ្តឹងសាទុក្ខ នៅពេលជំនុំជំរបានឆ្លើយថា ព្រោះសាលក្រមបានចូលជាស្ថាពរហើយ សាលាឧទ្ធរណ៍នៅតែយកមកកាត់ទៀត សំណូមពរសុំឱ្យសាលក្រមរបស់តុលាការក្រុងចូលជាស្ថាពរវិញ ដើម្បីយកទៅអនុវត្តតាមច្បាប់ ។

បានស្តាប់ចម្លើយរបស់មេធាវី.............តំណាងឱ្យលោកលហនិងលោកសយជាចុងចម្លើយនិងចុងបណ្តឹងសាទុក្ខ នៅពេលជំនុំជំរះបានឆ្លើយថា ខ្លួនសុំបដិសេធ ការលើកឡើងរបស់លោកចវវ ចោលទាំងស្រុង ព្រោះថាលោកលហនិងលោកសយដែលជាភាគីតំណាងឱ្យក្រុមហ៊ុននៃសាធារណរដ្ឋប្រជាមានិតចិន បានបញ្ជូនអ្នកបច្ចេកទេសពីប្រទេសចិន មករៀបចំរោងចក្រ ដំណើរការទៅមុខដាលំដាប់ ។ ឆ្លៀតឱកាសនេះលោកចវវ បានធ្វើពាក្យបណ្តឹងទៅតុលាការក្រុង សុំរំលាយកិច្ចសន្យា និងលក្ខន្តិកៈក្រុមហ៊ុនចោល ហើយថែមទាំងប្តឹងហាមឃាត់ និងប្តឹងសុំឱ្យអ្នកបច្ចេកទេស ដែលជាភាគីខាងលោកលូ ហូង សយចេញពីរោងចក្រក្នុងគោលបំណងកេងបន្លំយកភាគហ៊ុន និងដង្ហើមទាំងស្រុងលើក្រុមហ៊ុន ។

បានស្តាប់សចក្តីសន្និដ្ឋានរបស់មេធាវីលោក............នៅពេលជំនុំជំរះ ថា

សាលក្រមលេខ៦៧(ក) ចុះថ្ងៃទី២៧-០២-៩៨ របស់តុលាការក្រុង បានចូលជាស្ថាពរហើយ ហេតុនេះ ត្រូវបានតុលាការក្រុងភ្នំពេញចេញសេចក្តីសម្រេចលេខ២១៤៥ ត.រ ចុះថ្ងៃទី១៨-១១-៩៨ ដោយមូលហេតុប្តឹងក្រោយពេលសាលក្រមចូលជាស្ថាពរ ។ ដោយតុលាការក្រុងភ្នំពេញ បានជូន ដំណឹងទៅតាមច្បាប់អស់ហើយ ដូចជា បិទនៅលំនៅដ្ឋាន របស់ចុងចម្លើយ និងលើកក្រោយចូរតាមទំព័រ កាសែតទៀត ព្រមទាំងផ្ញើទៅតាមប្រពន្ធ័EMS ដែលជាប្រព័ន្ធរហ័សទាន់ចិត្ត តាមឯកសារភ្នំពេញ EMS ចំនួនពីរច្បាប់ ដែល EMS ម៉ាកាវ និងមិនបានបញ្ជាក់ថា បានប្រគល់ឱ្យសាម៉ីខ្លួន នៅថ្ងៃទី០៨-៤-៩៨ និងថ្ងៃទី១២-៤-៩៨ ។ លិខិតបញ្ជាក់លេខ៩៨ របស់ប្រធាននាយកដ្ឋានប្រសរើស៍ ផ្នែកប្រព័ន្ធEMS EE000058181 KH និង EE0000 58218 KH បានចែកដល់ដៃអ្នកនៅប្រទេសចិន និង ម៉ាកាវហើយ ។

-ទន្ទឹមនឹងនោះ ភាគីចាញ់ក្តីពុំសុខចិត្ត ក៏បានឡើងមកប្តឹងនៅសាលាឧទ្ធរណ៍ ពីសាលក្រមកំបាំងមុខស្ថាពរនេះ សាលាឧទ្ធរណ៍បែរជាទទួលចុះបណ្តឹងឧទ្ធរណ៍ ដែលខុសពីសមត្ថកិច្ចដែលច្បាប់បាន

កំណត់ ហើយសាលាឧទ្ធរណ៍បានលើកយកសំណុំរឿងក្តីនេះ មកជំនុំជំរះ បានសម្រេចសេចក្តីចេញសាលដីកាលេខ៥០៩ ចុះថ្ងៃទី២៩-០៧-៩៨ បដិសេធសាលក្រមស្ពាពរបស់តុលាការ ក្រុងភ្នំពេញចោល ហើយសម្រេចឱ្យភាគីកូនក្តី ខ្លួនចាញ់ក្តីយ៉ាងអយុត្តិធម៌ ចំណាត់ការរបស់សាលាឧទ្ធរណ៍ធ្វើយ៉ាងនេះ គឺមានការខុសឆ្គងនិងបំពានលើនីតិវិធីយ៉ាងធ្ងន់ធ្ងរ ពីព្រោះសាលាឧទ្ធរណ៍ពុំមានសមត្ថកិច្ចទទួលបណ្តឹងឧទ្ធរណ៍ហើយ ដោះស្រាយចេញសាលដីកា លើសាលក្រមស្ពាពរ របស់តុលាការក្រុងភ្នំពេញបានឡើយ ។

សាលាឧទ្ធរណ៍ទទួលស្គាល់លិខិតផ្ទេរសិទ្ធិរបស់ឈ្មោះលហានិងសយថាត្រឹមត្រូវដែលលិខិតនេះគ្មានលក្ខណៈគតិយុត្តិទេព្រោះលិខិតទាំងនេះជាភាសាចិន និងភាសាខ្មែរ ធ្វើនៅថ្ងៃតែមួយ ហើយ នៅប្រទេសចិនឯណាមិនមែននៅប្រទេសខ្មែរទេ ម៉្យាងទៀតសំអាងថា លិខិតផ្ទេរសិទ្ធិបញ្ជាក់ត្រឹមត្រូវ ពីមេធាវីចិន តើសាលាឧទ្ធរណ៍មានភស្តុតាងអីបញ្ជាក់ថាលោកឈឹង ចៀនស៊ីន ជាមេធាវីចិននោះ ការ បញ្ជាក់នេះក៏មិនបញ្ជាក់ថា លោកជាមេធាវី ឡើយ ដូច្នេះលិខិតនេះ គ្មានអានុភាពគតិយុត្តិទេ ដែលនាំឱ្យ ការផ្ទេរសិទ្ធិទៅលោក............ក៏មិនត្រឹមត្រូវដែរ ។

មានច្បាប់ណាដែលអនុញ្ញាតឱ្យតុលាការខ្មែរទទួលស្គាល់មេធាវីបរទេស បើសាលាឧទ្ធរណ៍ ទទួលស្គាល់ការបញ្ជាក់ និងប្រថាប់ត្រារបស់មេធាវីបរទេសដែលសរសេរអក្សរចិន គឺផ្ទុយនឹងច្បាប់ធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលជាច្បាប់កំពូលត្រង់មាត្រាទី៥ ។

**សំណូមពរៈ**

សូមឯកឧត្តម ក្រុមប្រឹក្សាជំនុំជំរះ សម្រេចបដិសេធ សាលដីការបស់សាលាឧទ្ធរណ៍ ដោយឥតបង្វិល និងសម្រេចតម្កល់ដីកាសម្រេចលេខ២១៤៥ គ.រ ចុះថ្ងៃទី១៨-១២-៩៨ ទុកជាបានការពេញទាំងមូល ដើម្បីចាត់ការអនុវត្តសាលក្រមស្ពាពរលេខ២៧(ក) តាមច្បាប់ ។

បានស្តាប់សចក្តីសន្និដ្ឋានរបស់មេធាវី លោក ............នៅពេលជំនុំជំរះ ថា

<u>អំពីចំណាត់ការរបស់តុលាការក្រុងភ្នំពេញ</u>

ការដែលតុលាការក្រុងភ្នំពេញ ជូនដំណឹងពីសាលក្រមកំបាំងមុខតាមរយៈ ចុះផ្សាយតាម ពត៌មានបិទនៅទីស្នាក់ការក្រុមហ៊ុនគឺសំរាប់តែភាគីដើមចោទ(ចារវេវ) មើលតែប៉ុណ្ណោះ ដោយហេតុថា កូនក្តីរបស់ខ្ញុំបាទ(លូហុង+ស៊ុនយ៉េ) បានចាកចេញពីប្រទេសកម្ពុជា ដោយព្រឹត្តការណ៍ ថ្ងៃទី៥-៦-៧-៩៧ អស់ទៅហើយ ។ ដូចជា ការបញ្ជាក់របស់ចៅសង្កាត់នៅលើខ្នងដីកាកោះ និងលិខិតជូនដំណឹងពីសាលក្រមកំបាំងមុខស្រាប់ ។

ចំពោះការជូនដំណឹងតាមរយៈEMS ក៏កូនក្តីខ្ញុំបាទពុំដែលបានឃើញ និងទទួលម្តងណាឡើយ តាមឯកសារដែលភាគីដើមចោទបានដាក់ជូនតុលាការ គឺឃើញមានតែឈ្មោះនៃអាសយដ្ឋាន និងហត្ថលេខា របស់អ្នកធ្វើចេញប៉ុណ្ណោះទេ ហើយលិខិតបែបនេះ នរណាក៏អាចធ្វើបានដែរ ឯស្នាមមេដៃអ្នកទទួលគឺពុំមានទាំងអស់ នេះសបញ្ជាក់យ៉ាងច្បាស់ថា ជាឯកសាររៀបចំឡើងដោយដើមចោទ និងការសុំ

ប្រគល់ពីតុលាការក្រុងភ្នំពេញ ដើម្បីឱ្យរឿងក្តីនេះចូលស្ថាពរបាន ។ ចំពោះឯកសារបញ្ជាក់ចេញពីក្រសួងព្រៃសណីយ៍ និងទូរគមនាគមន៍លេខ៧៩៨ ប.ចុះថ្ងៃទី១៩-៨-៨៩ និងលិខិតលេខ៩៩០.៩០១ ចុះថ្ងៃទី០៣-៩-៩៩ របស់ ក្រុមហ៊ុនធៀនពរចំកាត់គឺជាឯកសារថ្មីដែលភាគីដើមចោទ ធ្វើឡើងដោយខ្លួនឯង និងគ្មានតាមបញ្ជាពីតុលាការ ឡើយ ហើយតុលាការកំពូលមានសមត្ថកិច្ចជំនុំជំរះ តែទៅលើអង្គច្បាប់ប៉ុណ្ណោះ ពុំអនុញ្ញាពិឱ្យគូក្តីដាក់សំអាង បន្ថែមរឺ អង្កេតបន្ថែមនោះទេ ។

តុលាការក្រុងភ្នំពេញ ចាត់ការរឿងក្តីនេះ មានរយៈពេលតែ២ខែ ប៉ុណ្ណោះ រឿងចូលថ្ងៃទី០១-១២-៩៧ ជំនុំជំរះថ្ងៃទី២៧-០២-៨៨ គឺជាការប្រញាប់ប្រញាល់បំផុត។ តាមនីតិវិធី និងសារាចរណែនាំលេខ០៤សរធ៥៤ ចុះថ្ងៃទី២២-១១-៩៤ របស់ក្រសួងយុត្តិធមិត្រង់ចំណុចក-ខ និងធ បានបញ្ជាក់យ៉ាងច្បាស់ថា តុលាការត្រូវបង្អង់រឿងទុកមួយអន្លើសិន ប្រសិនបើតុលាការស្វែងរកគូក្តីណាមួយពុំទាន់ឃើញ ប៉ុន្តែក្នុងរឿងក្តីនេះ តុលាការក្រុងភ្នំពេញ បែរជាធ្វើការជំនុំជំរះ យ៉ាងប្រញាប់ប្រញាល់ទៅវិញ ។

នៅក្នុងរឿងក្តីនេះ តុលាការក្រុងភ្នំពេញ ទាំងភាគីដើមចោទសុទ្ធតែបានដឹងច្បាស់ថារាល់បណ្តាក្រុមហ៊ុនវិនិយោគធំៗ របស់មិនសុទ្ធតែជាក្រុមហ៊ុនចំនុះរដ្ឋ(មានភាគហ៊ុនរដ្ឋក្នុងនោះ) ហើយសុទ្ធតែបានដឹងថា នៅក្នុងប្រទេសកម្ពុជាយើងនេះ មានស្ថានទូតចិន តាំងនៅជាយូរណាស់មកហើយ ចុះហេតុអ្វី ក៏តុលាការក្រុងភ្នំពេញ ពុំបានជូនដំណឹងពីលិខិតផ្សេងៗរបស់ខ្លួន និងសាលក្រមកំបាំងមុខ តាមរយៈស្ថានទូត នេះទៅវិញ ។

ការលើកឡើង និងការបង្ហាញអំពីអំពើរបស់តុលាការក្រុងភ្នំពេញខាងលើនេះ សបញ្ជាក់ ឱ្យឃើញថា តុលាការក្រុងភ្នំពេញ បានឃុបឃិតជាមួយដើមចោទអនុវត្តផ្ទុយពីនីតិវិធី ហើយរឿងនេះមិនអាច ចូលជាស្ថាពរបានទេ ដោយហេតុថាគ្មានស្នាមមេដៃ ហត្ថលេខាទទួលលើសាលក្រមកំបាំងមុខពីកូនក្តីខ្ញុំបាទឡើយ ដូច្នេះគ្មានរយៈពេលណាមួយដែលអាចរាប់បាន១៥ថ្ងៃ(ផុតបណ្តឹងទាស់) និង២ខែផុតបណ្តឹងឧទ្ធរណ៍បានឡើយ ។

-អំពីចំណាត់ការរបស់សាលាឧទ្ធរណ៍

ក្រោយពីបានទទួលបណ្តឹងឧទ្ធរណ៍លើសេចក្តីសម្រេចលេខ២១៤៥តរ. ចុះថ្ងៃទី១៨-១១-៩៨ របស់តុលាការក្រុងភ្នំពេញ រួចមក សាលាឧទ្ធរណ៍ក៏បានលើករឿងនេះ មកចាត់ការតាមនីពីវិធី ដោយយល់ឃើញថា តុលាការក្រុងភ្នំពេញពុំអាចផ្តល់យុត្តិធម៌ក្នុងរឿងក្តីនេះបានកូនក្តីខ្ញុំបាទក៏បានព្រមព្រៀងគ្នាតាមរយៈសារណា ដាក់ជូនសាលាឧទ្ធរណ៍ សុំបោះបង់បណ្តឹងទាស់ចោល និងសុំប្តឹងឧទ្ធរណ៍តែម្តង ។ នៅថ្ងៃទី២៥-០២-៩៩ សាលាឧទ្ធរណ៍ក៏បានលើករឿងនេះ មកធ្វើការជំនុំជំរះ ដោយសម្រេចឱ្យចុះបណ្តឹងឧទ្ធរណ៍ និងចាត់ របៀប អង្កេតបន្ថែម បង្គាប់ឱ្យគូភាគីជូនសំអាងបន្ថែម ពេលនោះទាំងភាគីដើមចោទ ទាំងមេធាវីដើមចោទ ទាំងព្រះរាជអាជ្ញា ពុំមានការជំទាស់លើនីតិវិធីនេះឡើយ ហើយភាគីដើមចោទ ថែមទាំងដាក់សំអាងថ្មីជូន សាលាឧទ្ធរណ៍ទៀតផង ហើយការសម្រេចបែបនេះ របស់សាលាឧទ្ធរណ៍ ក៏បាន

ស្របទៅនឹងមាត្រា១៨៤ វាក្យខ័ណ្ឌ២ មាត្រា១៩៨ និងមាត្រា១៨៥ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌផងដែរ។ នៅថ្ងៃទី២៩-៧-៨៩ ក្រោយពីបានអង្កេត និង ទទួលបានសំអាងពីគូភាគី ពិសេសគឺទទួលបានលិខិតបញ្ជាក់ពីធនាគារ NDOSUEZ អំពីប្រាក់ដែលលហនិងសយបានបញ្ចូលមកដាក់ហ៊ុន និង រាល់ការបើកប្រាក់ពីលេខគណៈនេយ្យក្រុមហ៊ុន នេះ សុទ្ធតែមានហត្ថលេខាពីចវវ នោះ សាលាឧទ្ធរណ៍ក៏សម្រេចបើកសវនាការជាលើកទី២ ដោយសម្រេច ទទួលស្គាល់ភាគហ៊ុនឡើងវិញ តាមអំណាចសាលដីកាលេខ៥០៩/២៩-៧-៨៩ ខ្ញុំបាទសូមបញ្ជាក់ថា នៅ ពេលសវនាការអង្គសេចក្តីនេះ គឺគ្មានការជំទាស់ពីភាគីណាមួយឡើយ ពោលគឺដំណើរការនីតិវិធីដូចធម្មតា ប៉ុន្តែដោយភាគី ចវវ ដែលតែងតែមានបំណងរំលោភយកភាគហ៊ុន កូនក្តីខ្ញុំបាទទាំងពុំបានសម្រេចនោះទើបគាត់ប្តឹងសាទុក្ខមកតុលាការកំពូល ។

ផ្អែកតាមការលើកឡើងក្នុងសារណាក៏ដូចជាការសន្និដ្ឋាន របស់ដើមចោទ និងលោកមេធាវី ដើមចោទត្រង់ចំណុចសំណូមពរសុំឱ្យតុលាការកំពូល បដិសេធសាលដីការបស់សាលាឧទ្ធរណ៍ ដោយឥតបង្វិល និងសម្រេចតម្កល់ដីកាសម្រេចលេខ២១៤៥ តរ របស់តុលាការក្រុងភ្នំពេញនោះ ខ្ញុំបាទយល់ឃើញថា

-ប្រសិនបើតុលាការកំពូល សម្រេចតាមសំណូមពរនេះមែន នោះវាជាការសម្រេចផ្ទុយពីមាត្រា ២២១-២២៥ នៃច្បាប់ស្តីពីនិតិវិធីព្រហ្មទណ្ឌ ។

- បើតុលាការកំពូល យល់ឃើញថា សាលាឧទ្ធរណ៍ធ្វើខុសនីតិវិធីដោយលើកយករឿងមកធ្វើការជំនុំជំរះ ផ្ទុយពីបណ្តឹងឧទ្ធរណ៍នោះ វាជាកំហុសរបស់សាលាឧទ្ធរណ៍ តុលាការកំពូលត្រូវបដិសេធសាលដីកា របស់សាលាឧទ្ធរណ៍ ហើយបង្វិលសំណុំរឿងឱ្យសាលាឧទ្ធរណ៍ធ្វើការជំនុំជំរះ ជាថ្មីឡើងវិញ កូនក្តីខ្ញុំបាទបានដាក់ បណ្តឹងឧទ្ធរណ៍លើដីកាសម្រេចលេខ២១៤៥ តរ.ចុះថ្ងៃទី១៨-១១-៩៨ រួចហើយ ដូច្នេះ តុលាការកំពូលពុំគួរ បង្វិលកំហុសនីតិវិធីរបស់តុលាការ មកដាក់លើកូនក្តីខ្ញុំបាទឱ្យទទួលរងគ្រោះបាត់បង់ផលប្រយោជន៍អស់ប្រាក់ ប្រហែល១៣០ម៉ឺនដុល្លាអាមេរិក ដូច្នេះទេ ។

ហេតុដូច្នេះខ្ញុំបាទ សុំឱ្យតុលាការកំពូល ពិចារណា និងសម្រេចតម្កល់សាលដីកាលេខ៥០៩ ចុះថ្ងៃទី២៩-៧-៩៩ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល និងផ្តល់យុត្តិធម៌ដល់កូនក្តីខ្ញុំបាទទៅក្នុងរឿងក្តីនេះ តាមច្បាប់ ។

លោកមេធាវី .............បានធ្វើការឆ្លើយតបថា :

តុលាការគ្រាន់តែចេញលិខិតហើយ តែពេលផ្ញើមវិញ ឃើញមានស្នាមមេដៃរបស់ភាគី ម្ខាងនោះហើយ រួចក៏បានធ្វើលិខិតអញ្ជើញឱ្យមកចូលតុលាការទៀត ។

បញ្ហាលិខិតផ្ទេរសិទ្ធិគឺ ពុំមានលក្ខណៈត្រឹមត្រូវទេ ព្រោះវាពុំមានអានុភាពគតិយុត្តិទេ ចំណែកលោកសយបានផ្ញើលិខិតតាមប្រព័ន្ធ EMS មកហើយ ឯម៉ាស៊ីនវិញ គាត់ថា បានផ្ញើប្រាក់មក អស់ជាង១០០ម៉ឺនដុល្លា នោះពុំត្រឹមត្រូវទេ លុយដែលផ្ញើមកនេះ គឺជារបស់លោកទឹង តាំមិញ សំរាប់សង ថ្លៃ

សៅស៊ូទេ ជាការពិតណាស់ប្រាក់នេះ មិនមែនជារបស់លោកលហាទេ ធនាគារអាំងដូស៊ីអេ ក៏បាន បញ្ជាក់មកច្បាស់ណាស់ គឺវាស្របតាមនឹងថ្ងៃខែនោះទាំងអស់ប្រាកដណាស់លោកលហានិងលោក សយគឺចង់បានប្រយោជន៍ពីកូនក្តីខ្ញុំបាទទាំងស្រុង ។

លោកមេធាវី............បានធ្វើការឆ្លើយតបថា

ខ្ញុំបាទសូមបញ្ជាក់ ការលើកឡើងរបស់លោកមេធាវី ដើមចោទថា លិខិតផ្ទេរសិទ្ធិរបស់ខ្ញុំបាទពុំស្របច្បាប់ ដោយហេតុថា មានសរសេរជាអក្សរចិនផង អក្សរអង់គ្លេសផង និងអក្សរខ្មែរផង ហើយការបញ្ជាក់របស់មេធាវីចិនលើលិខិតនេះ មានចុះថ្ងៃ-ខែ-ឆ្នាំខុសគ្នានោះ ជាការពុំត្រឹមត្រូវទេ ព្រោះឯកសារ ជាភាសាបរទេស គេអាចបកប្រែបាន ឯការចុះថ្ងៃ-ខែ-ឆ្នាំខុសគ្នារបសមេធាវី លើស្នាមមេដៃ ឬ ហត្ថលេខានោះ ថាពិតប្រាកដនៅចំពោះមុខច្បាប់ ។

-ច្បាប់ហាមឃាត់តែលើមេធាវីបរទេសមិនអាចមកការពារនៅក្នុងតុលាការកម្ពុជាប៉ុណ្ណោះ មិនបានហាមឃាត់លើការបញ្ជាក់ក្នុងឯកសារណាបនោះទេ ។

- លោកសយនៅតែជាសមាជិកភាគហ៊ុននោះដដែល សំខាន់នៅលើការទទួលស្គាល់ របស់ក្រសួងពាណិជ្ជកម្ម ក្នុងលក្ខន្តិកៈបច្ចុប្បន្នក៏នៅមានឈ្មោះស៊ុន យ៉ៃ ដែរ មិនអាចយកលិខិតដែលគ្មាន ស្នាមមេដៃ រឺ ហត្ថលេខា របស់សយមកបញ្ជាក់ថាសយបានបោះបង់ភាគហ៊ុននោះឡើយ ។ នៅសាលាឧទ្ធរណ៍ ភាគីដើមចោទបានអនុវត្តតាមដីកាចាត់របៀបត្រឹមត្រូវហើយ ព្រមទាំងបានជូនសំអាងថ្មីរៀងៗខ្លួនរួចហើយ ។

ប្រាក់ដែលមេធាវីថា ជារបស់ក្រុមហ៊ុន យូតែឡុង ជាការមិនពិតទេ ព្រោះពេលនោះក្រុមហ៊ុននេះមិនទាន់កើតផង ហេតុអ្វីបានទៅជាប្រាក់របស់ក្រុមហ៊ុននេះកើត ។

លោកមេធាវី............បានធ្វើឆ្លើយតបថាៈ

លិខិតដែលខ្ញុំបាទបានជូនឯកឧត្តមនេះ គឺមានការបញ្ជាក់ត្រឹមត្រូវណាស់ ព្រោះមានលេខគណនេយ្យរបស់លោកចវ ។

-ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ ĸ

-ក្រោយពីបានស្តាប់ចម្លើយ របស់លោកចវ និង តំណាងរបស់លោកលហានិង លោក សយសេចក្តីសន្និដ្ឋានរបស់មេធាវី នៃគូភាគី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ.

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ៤១២ ចុះថ្ងៃទី២៣-៩-៩៩ របស់លោកចាវ វេវរ និងលោកស្រីសថវ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើកយករឿងនេះ មកជំនុំជំរះ បានតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាព របស់សាលាជំរះក្តី ។

-យល់ឃើញថា សាលាឧទ្ធរណ៍ បានបំពានទៅលើមាត្រា៧ វាក្យខណ្ឌ២ និងមាត្រា ៨ វាក្យខណ្ឌទី៣ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី និងមាត្រា១៧៨ នៃច្បាប់ស្តីពី នីតិវិធីព្រហ្មទណ្ឌដោយបានលើកយកបណ្តឹងឧទ្ធរណ៍ ដែលហួសរយៈពេលប្តឹងឧទ្ធរណ៍ហើយមកដោះស្រាយ ។

-យល់ឃើញថា តុលាការក្រុងភ្នំពេញ បានជូនដំណឹងពីសាលក្រមកំបាំងមុខលេខ២៧ ក ចុះថ្ងៃទី២៧-០២-៩៨ ដល់លោកលហ( LUO HONG)និងលោកសយតាមរយៈEMS ដោយមានEE000058.18. KH S1EE00005328KH ហើយដែល PPEMs inquiry បានបញ្ជាក់ថា EMS Macauនិងចិនឲ្យសាម៉ីខ្លួននៅថ្ងៃទី០៨-៤-៩៨ និង នៅថ្ងៃទី១២-៤-៩៨ រួចហើយ ។

-យល់ឃើញថាលោកសយ(JINGE)និងលោកម៉ាទា ពីង ( MATEPING ) ដែលបានទទួលសិទ្ធិពីលោកលហ(LUOHONG) និងលោកសយនៅថ្ងៃ០៣-១១-៩៨ ហើយបានយប្តឹងទាស់និងប្តឹងឧទ្ធរណ៍លើសាលដីក្រមលេខ២៧ ក ចុះថ្ងៃទី២៧-០២-៩៨ របស់តុលាការក្រុងភ្នំពេញ នៅថ្ងៃ១៦-១១-៩៨ នោះគឺហួសរយៈពេលប្តឹងទាស់ និងប្រឹងឧទ្ធរណ៍ដែលត្រូវគិតចាប់ពីថ្ងៃ០៨-៤-៩៨ និង១២-៤-៩៨ ហើយ ។

-យល់ឃើញថា សាលដីកា រដ្ឋប្បវេណីលេខ៥០៩ ចុះថ្ងៃទី២៩-៧-៩៩ របស់សាលាឧទ្ធរណ៍ដែលបានសម្រេចសេចក្តីមកនេះ មានលក្ខណៈខុសឆ្គងទាំងទម្រង់ ទាំងគតិច្បាប់ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តីចំពោះមុខ ដើមចោទ និង តំណាងចុងចម្លើយ ចាត់ទុកជាចំពោះមុខគូភាគី

១- ទទួលបណ្តឹងសាទុក្ខលេខ៤១២ ចុះថ្ងៃទី២៣-៩-៩៩ របស់លោកចវ និងអ្នកស្រីសថវ ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២- ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ៥០៩ ចុះថ្ងៃទី២៩-៧-៩៩ របស់សាលាឧទ្ធរណ៍ទាំងមូល ដោយឥតបង្វិល ។

៣- បញ្ជូនសំណុំរឿងរដ្ឋប្បវេណីលេខ៣៧៥ ចុះថ្ងៃទី០១-១២-៥៩ របស់តុលាការកំពូល នៅតុការក្រុងភ្នំពេញ ដើម្បីអនុវត្តតាមច្បាប់ ។

៤- រឹបអូសប្រាក់ប្រដាប់ក្តី ចំនួន១៨,០០០រៀល ដែលលោកចវ និងអ្នកស្រីសថវ បានបង់រួចហើយគឺ :

-ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន ៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀល សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ .

-ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០រៀល សរុប១៩០០០រៀល ហើយតម្រូវឱ្យលោកជីន ហ្សេ(JINGE)និងលោកម៉ា ទាពីង(MATEPING)សងប្រាក់១៩.០០០រៀលនេះ ឱ្យលោកចវ និង អ្នកស្រីសថវ វិញ ។

៥- សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០០ ។